**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខ ....០២៥/២៦............ក.ប/ស.ណ.ន.បា.ទ.រ

# សេចក្តីណែនាំបន្ថែម
## ស្តីពី
## ការចូលរួមសន្សំសំចៃការប្រើប្រាស់ថាមពលអគ្គិសនី

ដើម្បីចូលរួមសន្សំសំចៃការប្រើប្រាស់ថាមពលអគ្គិសនី ក្នុងស្ថានភាពដែលពិភពលោកកំពុងប្រឈមនឹងវិបត្តិផ្គត់ផ្គង់ និងការកើនឡើងថ្លៃប្រេងឥន្ធនៈជាបន្តបន្ទាប់ក្នុងអំឡុងពេលនៃសភាពការណ៍ជម្លោះនៅតំបន់មជ្ឈិមបូព៌ា ក្រសួងសូមធ្វើការណែនាំបន្ថែមដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ ដែលកំពុងបម្រើការងារនៅតាមបណ្តាគ្រប់អង្គភាពក្រោមឱវាទក្រសួង ត្រូវរួមគ្នាចូលរួមសន្សំសំចៃការប្រើប្រាស់ថាមពលអគ្គិសនីតាមវិធានការដូចខាងក្រោម៖

១- ត្រូវកំណត់សីតុណ្ហភាពម៉ាស៊ីនត្រជាក់ក្នុងបន្ទប់ការិយាល័យ សាលប្រជុំនានា ឬបន្ទប់សិក្សា ត្រឹមឬលើសពី ២៥អង្សាសេ ចៀសវាងប្រើប្រាស់ម៉ាស៊ីនត្រជាក់លើសពីតម្រូវការ។

២- ត្រូវបិទអំពូលភ្លើង ម៉ាស៊ីនត្រជាក់ និងដកឌុយចេញពីឧបករណ៍បរិក្ខារអគ្គិសនីគ្រប់ប្រភេទដែលមិនចាំបាច់ ឬនៅពេលឈប់ប្រើប្រាស់ នៅពេលម៉ោងសម្រាក និងមុនពេលចាកចេញពីបន្ទប់ការិយាល័យ សាលប្រជុំ ឬបន្ទប់សិក្សា។

៣- ចំពោះការបំភ្លឺទីសាធារណៈ ឬតាមរបង ត្រូវកំណត់ពេលបើក-បិទ ឱ្យបានត្រឹមត្រូវ និងខ្ជាប់ខ្ជួន ចៀសវាងបំភ្លឺពេលមិនទាន់ងងឹត និងបើកចោលពេលព្រឹក នៅពេលមានពន្លឺថ្ងៃ។

៤- លើកទឹកចិត្តឱ្យបើកវាំងននប្រើប្រាស់ពន្លឺព្រះអាទិត្យឱ្យអស់លទ្ធភាព ជំនួសការបើកអំពូលភ្លើង។

៥- ត្រូវបិទសេចក្តីណែនាំបន្ថែមនេះ នៅតាមទីតាំងដាក់ឧបករណ៍អគ្គិសនីប្រើប្រាស់។ ឧទាហរណ៍៖ នៅបន្ទប់ម៉ាស៊ីនថតចម្លងឯកសារ "សូមបិទម៉ាស៊ីនក្រោយប្រើប្រាស់រួច"។

ទទួលបានសេចក្តីណែនាំនេះ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១០រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៦

**រដ្ឋមន្ត្រី**

**ហេង សួរ**

**កន្លែងទទួល៖**
- គ្រប់ថ្នាក់ដឹកនាំក្រសួង
- គ្រប់អង្គភាពក្រោមឱវាទក្រសួង
- ឯកសារ កាលប្បវត្តិ

*UNOFFICIAL TRANSLATION*

**KINGDOM OF CAMBODIA**

**Nation Religion King**

**Ministry of Labour and Vocational Training**

No: 025/26 K.B/S.Nor.N.Hor.T.R

## Additional Instruction
## On
## Participation in Conserving Electricity Consumption

To contribute to the conservation of electricity during the current global energy crisis and the continuous rise in fuel prices caused by conflict in the Middle East, the Ministry would like to provide additional instructions to all levels of management and officials working at entities under the Ministry to participate in conserving electricity as follows:

1. Set air conditioning temperatures in offices, meeting rooms, or classrooms at or higher than 25°C to avoid excessive energy use.
2. Turn off lights, air conditioners, and unplug all types of electrical equipment when they are not necessary or when stop using them, during break times, and before leaving offices, meeting rooms, or classrooms.
3. For public lighting or hallway lights, set specific times for turning them on and off to avoid lighting them before the sky gets dark or leave them turn on in the morning when there is sufficient sunlight.
4. Encourage the opening of curtains to utilize natural sunlight instead of turning on light bulbs.
5. Post this Additional Instruction near electrical equipment. For example: near a photocopier: "Please turn off after use").

Upon receiving this instruction, all Excellencies, Ladies, and Gentlemen who are the management and officials must strictly and effectively implement these measures from the date of signature onward.

**Phnom Penh, 13th March 2026**

**Minister**

*(signed and stamped)*

**HENG SOUR**

CAMFEBA
Unofficial Translation

**Recipients:**

- All levels of Ministry's management
- All entities under the Ministry
- Archives

GOLD CORPORATE PARTNER
Forte Life Assurance
GOLD BRANDING PARTNERS
MEGA We care
Aplus Consulting Co., Ltd.
ANANT LAW FIRM
SOK XING & HWANG
PROVITA